# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

BAYON ERA HOTEL
巴戎时代酒店
*Reliving the Exotic Past of Bayon*
★★★★★

## កិច្ចព្រមព្រៀង

## រវាងនិយោជក និង និយោជិតក្នុងការព្យួរអាជីវកម្មបណ្ដោះអាសន្នរបស់សណ្ឋាគារបាយ័ន អេរ៉ា ហូថែល ខបភើរេសិន

នាងខ្ញុំ គឺ មុយឡេង ភេទ ស្រី សញ្ជាតិ ខ្មែរ ជាម្ចាស់ សណ្ឋាគារបាយ័នអេរ៉ា ហូថែល ខបភើរេសិន ដែលមានទីតាំងស្ថិតនៅភូមិ ខ្នារ សង្កាត់ ជ្រាវ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលតំណាងឲ្យ ភាគី "ក"។

និយោជិតទាំងអស់ដែលបំរើការងារនៅក្នុង សណ្ឋាគារបាយ័នអេរ៉ា ហូថែល ខបភើរេសិន ដែលមានទីតាំងស្ថិតនៅភូមិ ខ្នារ សង្កាត់ ជ្រាវ ក្រុង សៀមរាប ខេត្ត សៀមរាប ដែលតំណាងឲ្យ ភាគី "ខ"។

សណ្ឋាគារបាយ័ន អេរ៉ា ហូថែល ខបភើរេសិន នឹងត្រូវផ្អាកដំណើរការអាជីវកម្មជាបណ្ដោះអាសន្ន ចាប់ពីថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០២១ ដោយសារយើងខ្ញុំ កំពុងជួបប្រទះគ្មានភ្ញៀវស្នាក់នៅដែលបណ្ដាលមកពីវិបត្តិសកលនៃមេរោគ កូវីត១៩ ជាហេតុធ្វើអោយសណ្ឋាគារ គ្មានប្រាក់ចំណូលដើម្បីប្រតិបត្តិការអាជីវកម្មទៀតបាន។

សណ្ឋា
បាយ័ន
BAYON ERA

ដូចច្នេះទើបក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារបុគ្គលិកចំនួន ១២៥នាក់ ចំពោះការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុន (និយោជក) មិនបានផ្ដល់ប្រាក់ឧបត្ថមជូនកម្មករនិយោជិតទេ ដោយក្រុមហ៊ុនបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងប្រតិភូបុគ្គលិករួមទាំងប្រធានក្រុមរហូតដល់មានការព្រមព្រៀងដូចខាងក្រោមៈ

ប្រការមួយៈ និយោជក(ភាគី"ក" ) រក្សាកិច្ចសន្យាការងាររបស់បុគ្គលិកនៅដដែល និងអត្ថប្រយោជន៍ផ្សេងៗ ដូចដែលមានចែងក្នុងកិច្ចសន្យាការងាររបស់សណ្ឋាគារ បាយ័នអេរ៉ា ហូថែល ខបភើរេសិន

ប្រការពីៈ និយោជិត (ភាគី "ខ" ) បានព្រមព្រៀងក្នុងការព្យួរកិច្ចសន្យាកាងាររបស់ សណ្ឋាគារបាយ័នអេរ៉ា ហូថែល ខបភើរេសិន ដូចដែលបានរៀបរាប់ខាងលើ

ដើម្បីឲ្យប្រាកដ យើងខ្ញុំទាំងពីរភាគី សូមធ្វើការផ្ដិតស្នាមមេដៃស្ដាំទុកជាភស្តុតាង។

សៀមរាប ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០

ភាគី "ក"

គី មុយឡេង

ឈ្មោះ និងស្នាមមេដៃស្ដាំភាគី "ខ"

| | | |
|---|---|---|
| ឈ្មោះ<br>តួនាទី | ឈ្មោះ<br>តួនាទី | ឈ្មោះ<br>តួនាទី |
| ឈ្មោះ<br>តួនាទី | ឈ្មោះ<br>តួនាទី | ឈ្មោះ<br>តួនាទី |

BAYON ERA HOTEL